ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អគ្គលេខាធិការដ្ឋាន
លេខ: ០៧៥ គ.ជ.ប.អគ្គ

ថ្ងៃចន្ទ ១០កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយ នៅលើសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

ផ្អែកតាមលទ្ធផលនៃការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅលើសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលត្រូវបានធ្វើឡើងនៅទីស្តីការ គ.ជ.ប នៅព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ទាំង ១៨ គណបក្ស ទទួលបានលំដាប់លេខរៀង ដូចខាងក្រោម៖

| លំដាប់លេខរៀង | ឈ្មោះគណបក្សនយោបាយ | លំដាប់លេខរៀង | ឈ្មោះគណបក្សនយោបាយ |
|---|---|---|---|
| ១ | គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ | ១០ | គណបក្សធម្មាធិបតេយ្យ |
| ២ | គណបក្សខ្មែរតែមួយ | ១១ | គណបក្សប្រជាធិបតេយ្យមូលដ្ឋាន |
| ៣ | គណបក្សសញ្ញាតិកម្ពុជា | ១២ | គណបក្សបំណងពលរដ្ឋ |
| ៤ | គណបក្សខ្មែររួបរួមជាតិ | ១៣ | គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច |
| ៥ | គណបក្សកម្លាំងប្រជាធិបតេយ្យ | ១៤ | គណបក្សឯកភាពជាតិខ្មែរ |
| ៦ | គណបក្សកសិករ | ១៥ | គណបក្សខ្មែរអភិរក្ស |
| ៧ | គណបក្សស្ត្រីដើម្បីស្ត្រី | ១៦ | គណបក្សយុវជនកម្ពុជា |
| ៨ | គណបក្សខ្មែរឈប់ក្រ | ១៧ | គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា |
| ៩ | គណបក្សហ៊្វុនស៊ិនប៉ិច | ១៨ | គណបក្សប្រជាជនកម្ពុជា |

សូមជម្រាបជូនថា ការប្រព្រឹត្តទៅនៃការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅលើសន្លឹកឆ្នោត បានធ្វើឡើងជាសាធារណៈ និងមានលំដាប់លំដោយ តាមការកំណត់ក្នុងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។ ក្នុងនោះ **សម្តេចព្រះអគ្គមហាសង្ឃរាជទាំងពីរគណៈ** បាននិមន្តយាងព្រះរាជប្រទានចាប់ឆ្នោត នៅចំពោះមុខ ឯកឧត្តមប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប តំណាងគណបក្សនយោបាយ ទាំង ១៨ គណបក្ស តំណាងក្រសួង ស្ថាប័នជាតិពាក់ព័ន្ធ មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប តំណាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានជាតិ-អន្តរជាតិជាច្រើន។